ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សាលក្រមរដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណីលេខ៖ ០៤៤
ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២
សាលក្រមរដ្ឋប្បវេណីលេខ៖ ៤៥ (ង)
ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២

**តាមនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្ដាល**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២

**សមាសភាពជំនុំជម្រះ**

លោក [redacted] ចៅក្រមសសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**ដើមចោទ÷**

+ឈ្មោះ [redacted]សាវី ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ មុខរបរ ជាតំណាងឲ្យក្រុមហ៊ុន [redacted] មានទីតាំងស្ថិតនៅផ្ទះលេខ [redacted] មានលោក [redacted] អត្តលេខ:១០១៦ និងលោកស្រី [redacted] អត្តលេខ:២៥២៩T ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ។

**ចុងចម្លើយ÷**

+ឈ្មោះ [redacted]សុវ៉ាន់ ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ និងប្រពន្ធឈ្មោះ [redacted] ស្រីមុំ អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted] ។

**អង្គហេតុ និងការអះអាងរបស់គូភាគី**

**១. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ÷**

១.១. បង្គាប់ឲ្យភាគីចុងចម្លើយសងប្រាក់ដើមមកដើមចោទចំនួន៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក ។



Scanned with CamScanner

១.២. បង្គាប់ឲ្យភាគីចុងចម្លើយបង់ការប្រាក់មកឲ្យភាគីដើមចោទចំនួន១១,៨១០ (មួយម៉ឺនមួយពាន់ប្រាំបីរយដប់) ដុល្លារអាមេរិក គិតចាប់ពីខែសីហា ឆ្នាំ២០២០ រហូតដល់ខែមករា ឆ្នាំ២០២២ ។

១.៣. បង្គាប់ឲ្យភាគីចុងចម្លើយបង់ការប្រាក់១៨% ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក គិតចាប់ពីខែមករា ឆ្នាំ២០២២ រហូតដល់សងប្រាក់ដើមគ្រប់ចំនួន។

១.៤. បង្គាប់ឲ្យភាគីចុងចម្លើយសងសំណងជំងឺចិត្ត និងការខាតបង់ផ្សេងៗចំនួន ២០,០០០,០០០ (ម្ភៃលាន) រៀល ឲ្យមកភាគីដើមចោទ ។

១.៥. សុំអនុវត្តជាបណ្ដោះអាសន្នលើប្រាក់ដើម ។

**២. អង្គហេតុដែលភាគីអះអាង និងចំណុចវិវាទ**

២.១. រឿងក្ដីនេះ លោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្ដីថ្លែងការណ៍ថា៖ នៅពេលនេះ នាងខ្ញុំ ហង់ ចរិយា ជាមេធាវីតំណាងឲ្យដើមចោទស្នើសុំតុលាការបន្តនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃនេះ ដោយហេតុថា អាជ្ញាសាលាបានធ្វើការបញ្ជូនដីកាកោះទៅភាគីចុងចម្លើយត្រឹមត្រូវតាមនីតិវិធីរួចហើយ។ នៅក្នុងរឿងនេះ នាងខ្ញុំសូមរក្សាខ្លឹមសារនៃការទាមទារដូចមាននៅក្នុងពាក្យបណ្ដឹង ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ២០២២ និងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី១ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ និងលើកទី២ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ ទុកជាបានការដដែល។ នាងខ្ញុំសូមបញ្ជាក់បន្ថែមថា កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ រវាងដើមចោទ និងចុងចម្លើយ គឺធ្វើឡើងត្រឹមត្រូវតាមផ្លូវច្បាប់ ដោយពុំមានវិការៈណាមួយនៃកិច្ចសន្យាឡើយ ហើយកិច្ចសន្យានេះ កើតឡើងរវាងឆន្ទៈរបស់ភាគីពិតប្រាកដមែន។ ប៉ុន្តែក្រោយពេលដែលចុងចម្លើយទទួលបានប្រាក់កម្ចីរួច ចុងចម្លើយពុំបានអនុវត្តកាតព្វកិច្ចបង់ការប្រាក់ និងប្រាក់ដើមមកឲ្យដើមចោទឡើយ ដោយចេះតែបន្តគេចវេសរហូតមកដល់សព្វថ្ងៃ ដូចមាននៅក្នុងភស្តុតាងដែលបានដាក់ជូនតុលាការ គឺបានបញ្ជាក់ថា ចុងចម្លើយបានទទួលស្គាល់បំណុលដែលជំពាក់ដើមចោទពិតប្រាកដមែន។ ហេតុនេះ ស្នើសុំឲ្យតុលាការសម្រេចតាមការទាមទាររបស់ដើមចោទគ្រប់ចំណុចទាំងអស់ និងសុំអនុវត្តសាលក្រមជាបណ្ដោះអាសន្ន ។

២.២. អង្គហេតុដែលគ្មានវិវាទ

កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ កូនបំណុលឈ្មោះ [redacted] សុខវ៉ាន់ និងប្រពន្ធឈ្មោះ [redacted] ស្រីមុំ បានមកខ្ចីប្រាក់ពីក្រុមហ៊ុន [redacted] ដែលមានលោក [redacted] សាវី ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ ជាតំណាង នូវទឹកប្រាក់ចំនួន៣០០០០ (បីម៉ឺន) ដុល្លារអាមេរិក តាមរយៈកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ ដោយសន្យាថា ខ្ចីប្រាក់រយៈពេលតែ០៦ខែប៉ុណ្ណោះ ។ ពោលគឺ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៩ ពួកគេនឹងសងប្រាក់ដើម និងការប្រាក់គ្រប់ចំនួនដល់ដើមចោទវិញ។ លុះដល់កាលបរិច្ឆេទកំណត់សងប្រាក់ខាងលើ ភាគីចុងចម្លើយពុំមានលទ្ធភាពសងប្រាក់មកឲ្យដើមចោទវិញឡើយ។ ភាគីចុងចម្លើយបានស្នើសុំបន្តកិច្ចសន្យាខ្ចីសុំពន្យាសងប្រាក់ដើមចំនួន០២ខែបន្តទៀត ពោលគឺភាគីចុងចម្លើយសន្យាសងប្រាក់ដើម និងការប្រាក់មកឲ្យដើមចោទនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩។ ប៉ុន្តែផ្ទុយទៅវិញ នៅពេលដល់កាលបរិច្ឆេទខាងលើ ភាគីចុងចម្លើយនៅតែពុំបានសងប្រាក់មកដើមចោទ ក៏បានស្នើសុំខ្ចីប្រាក់ដើមចោទបន្តទៀត។ ដោយបានធ្វើកិច្ចសន្យាសុំពន្យាពេលសងប្រាក់ដើមជាលើកទី២ នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២០ ហើយសន្យាថា នឹងសងប្រាក់ដើម និងការប្រាក់ឲ្យដើមចោទ នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ ។

២.៣. ចំណុចវិវាទ

តើការទាមទាររបស់ដើមចោទដែលមាននៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ មានភាពត្រឹមត្រូវដែរឬទេ?

**សំអាងហេតុ**

១. ការវិនិច្ឆ័យអំពីចំណុចវិវាទ

យោងតាមការទាមទាររបស់ដើមចោទដែលមាននៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ឃើញថា ការទាមទារនេះមានភាពត្រឹមត្រូវស្របតាមមាត្រា ៥៧៨,៥៨៣ នៃក្រមរដ្ឋប្បវេណី។ ហេតុដូច្នេះ គប្បីតុលាការពិចារណាសម្រេចតាមការទាមទាររបស់ដើមចោទ ។

២. ការវិនិច្ឆ័យអំពីការទាមទារ

យល់ឃើញថា ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ រវាងដើមចោទ និងសហចុងចម្លើយ អាចបញ្ជាក់បានថា ភាគីចុងចម្លើយពិតជាបានព្រមព្រៀងខ្ចីប្រាក់ដើមពីភាគីដើមចោទចំនួន៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក ប្រាកដមែន ។ ហេតុនេះ ការដែលភាគីដើមចោទទាមទារប្រាក់ដើមចំនួន៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក ពីភាគី

ចុងចម្លើយ ឃើញថា មានភាពត្រឹមត្រូវ ស្របតាមបញ្ញត្តិមាត្រា៤៧៨,៤៧៩ នៃក្រមរដ្ឋប្បវេណី ។ ហេតុដូច្នេះ គប្បីឲ្យតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ។

***យល់ឃើញថា៖*** ដើមចោទទាមទារមកតុលាការឲ្យបង្គាប់ឲ្យចុងចម្លើយបង់ការប្រាក់មកឲ្យភាគីដើមចោទចំនួន**១១,៨១០ (មួយម៉ឺនមួយពាន់ប្រាំបីរយដប់) ដុល្លារអាមេរិក** គិតចាប់ពីខែ**សីហា** ឆ្នាំ២០២០ រហូតដល់ខែ**មករា** ឆ្នាំ២០២២ ឃើញថា ការទាមទារនេះ មានភាពត្រឹមត្រូវ ព្រោះផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ ភាគីចុងចម្លើយព្រមព្រៀងបង់ការប្រាក់ចំនួន២,៥% ក្នុងមួយខែ ឲ្យទៅដើមចោទ ។ ហេតុដូច្នេះ គប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ ។

***យល់ឃើញថា*** ដើមចោទទាមទារឲ្យភាគីចុងចម្លើយបង់ការប្រាក់១៨% ក្នុងមួយឆ្នាំលើប្រាក់ដើមចំនួន៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក គិតចាប់ពីខែ**មករា** ឆ្នាំ២០២២ រហូតដល់សងប្រាក់ដើមគ្រប់ចំនួន ឃើញថា ការទាមទារនេះ ស្ថិតនៅក្នុងកម្រិតមួយដែលច្បាប់អនុញ្ញាត។ ដូចនេះ តុលាការគប្បីសម្រេចតាមការទាមទារ ស្របតាមប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតលេខ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ ត្រង់សេចក្តីសម្រេច ប្រការ១ ចែងថា: អត្រាការប្រាក់ដែលត្រូវបានកម្រិតដែលបានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា១៧ (អត្រាការប្រាក់ដែលត្រូវបានកម្រិតជាអាទ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពី ១៨%(ដប់ប្រាំបី) ភាគរយ ក្នុង០១ (មួយ) ឆ្នាំ។

***យល់ឃើញថា*** ដើមចោទទាមទារសំណងជំងឺចិត្ត និងការខាតបង់ផ្សេងៗចំនួន ២០,០០០,០០០ (ម្ភៃលាន) រៀល ពីចុងចម្លើយ ឃើញថា ការដែលចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនស្របតាមកិច្ចសន្យា ពិតជាធ្វើឲ្យដើមចោទខាតបង់ពេលវេលា ខូចខាតផលប្រយោជន៍របស់ដើមចោទទៀតផង។ ឃើញថា ការស្នើសុំរបស់ដើមចោទពិតជាមានភាពត្រឹមត្រូវ គប្បីតុលាការសម្រេចតាមទំហំនៃការខូចខាតជាក់ស្តែង ស្របតាមមាត្រា ៤០០,៤០១ នៃក្រមរដ្ឋប្បវេណី ។

***យល់ឃើញថា*** ដើមចោទសុំឲ្យតុលាការប្រកាសថាសាលក្រមនេះមានអានុភាពអនុវត្តបណ្តោះអាសន្នត្រង់ចំណុចប្រាក់ដើម ដែលចំណុចនេះ តុលាការពិចារណាឃើញថាមានភាពច្បាស់លាស់ដែលបញ្ជាក់ថា សហចុងចម្លើយពិតជាបានជំពាក់ប្រាក់ដើមចំនួន ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក ប្រាកដមែន។ ប្រសិនបើមិនអនុញ្ញាតឲ្យមានការអនុវត្តជាបណ្តោះអាសន្នទេនោះ អាចធ្វើឲ្យបាត់បង់ផលប្រយោជន៍របស់ដើមចោទកាន់



Scanned with CamScanner

តែធូន់ធ្ងរ ទម្រាំតែសាលក្រមចូលជាស្ថាពរ ។ ហេតុដូច្នេះ គប្បីតុលាការទទួលស្គាល់ការទាមទារនេះស្របតាមបញ្ញត្តិមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**យល់ឃើញថា** កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ តុលាការបានចេញដីកាកោះហៅភាគីឲ្យមកចូលមកធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ តុលាការបានចេញដីកាកោះហៅភាគីឲ្យចូលរួមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដោយបានធ្វើការបញ្ជូនយ៉ាងត្រឹមត្រូវទៅភាគីតាមរយៈមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន។ ចំពោះដីកាកោះហៅភាគីចុងចម្លើយឈ្មោះ [redacted] សុវ៉ាន់ និងប្រពន្ធឈ្មោះ [redacted] ស្រីមុំ ទាំងពីរលើក និងពាក្យបណ្តឹងរបស់ដើមចោទ ត្រូវបានមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន បញ្ជូនទៅដល់អាសយដ្ឋានរបស់ភាគីចុងចម្លើយហើយ ។ ប៉ុន្តែនៅពេលដល់កាលកំណត់ចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ សហចុងចម្លើយឈ្មោះ [redacted] សុវ៉ាន់ និងប្រពន្ធឈ្មោះ [redacted] ស្រីមុំ អវត្តមានដោយគ្មានមូលហេតុឡើយ។ ចំពោះការអវត្តមានរបស់ភាគីចុងចម្លើយ ដោយគ្មានមូលហេតុនេះ តុលាការយល់ឃើញថា ចុងចម្លើយបានសារភាពទទួលស្គាល់នូវសេចក្តីថ្លែងការណ៍របស់ភាគីដើមចោទ ទាក់ទងនឹងអង្គហេតុ ដែលចំណុចនេះ គប្បីតុលាការពិចារណាតាមបញ្ញត្តិមាត្រា២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៣.ប្រាក់ប្រដាប់ក្តីគប្បីអនុវត្តតាមមាត្រា៦២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ហេតុដូច្នេះ តុលាការ ធ្វើការវិនិច្ឆ័យដូចខាងក្រោមៈ

**សេចក្តីសម្រេចបញ្ចប់**

១. បង្គាប់ឲ្យភាគីចុងចម្លើយសងប្រាក់ដើមមកដើមចោទចំនួន៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក ។

២.បង្គាប់ឲ្យភាគីចុងចម្លើយបង់ការប្រាក់មកឲ្យភាគីដើមចោទចំនួន១១,៨១០(មួយម៉ឺនមួយពាន់ប្រាំបីរយដប់) ដុល្លារអាមេរិក គិតចាប់ពីខែសីហា ឆ្នាំ២០២០ រហូតដល់ខែមករា ឆ្នាំ២០២២ ។

៣. បង្គាប់ឲ្យភាគីចុងចម្លើយបង់ការប្រាក់១៨% ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក គិតចាប់ពីខែមករា ឆ្នាំ២០២២ រហូតដល់សងប្រាក់ដើមគ្រប់ចំនួន។



Scanned with CamScanner

៤. បង្គាប់ឲ្យកាតីចុងចម្លើយសងសំណងជំងឺចិត្ត និងការខាតបង់ផ្សេងៗចំនួន ៨,០០០,០០០ (ប្រាំបីលាន) រៀល ឲ្យមកភាគីដើមចោទ ។

៥. សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបាននៅត្រង់ចំណុចទី១ នៃសេចក្តីសម្រេចខាងលើ ។

សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០២២ នៅចំពោះមុខមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ។

ទុកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

ថ្ងៃអង្គារ ១៤រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ខេត្តកណ្តាល, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២

**ចៅក្រម**

**ហត្ថលេខា និងត្រា៖** [redacted]

---

**បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃអង្គារ ១៤រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

នៅខេត្តកណ្តាល, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]



Scanned with CamScanner